| កិច្ចតែងការ | |
|---|---|
| មុខវិជ្ជា | សិក្សាសង្គម/ចិត្តចលភាព |
| ប្រធានបទ | សិក្សាសង្គម:គំនូរ និងសកម្មភាពកសាង<br>ចិត្តចលភាព:ការរីកចម្រើនរាងកាយ និងចលនា |
| ចំណងជើងមេរៀន | ល្បែងវដ្តនៃទឹកភ្លៀង(ដកស្រង់ពីរឿងតើនរណាជាអ្នកលាបពណ៌មេឃ) |
| កម្រិត | មធ្យម ៣០ នាទី |
| គោលបំណង | -គូរ និងផាត់ពណ៌ដើម្បីបង្កើតរូបភាពផ្សេងៗ និងបង្ហាញពីអ្វីដែលគេបានបង្កើត។<br>-កុមារចេះធ្វើកាយវិការតាមសកម្មភាពផ្សេងៗ |
| បំណិនសម្បទា | -គូរនិងផាត់ពណ៌រូបគំនូរវដ្តនៃទឹកភ្លៀងបានត្រឹមត្រូវ។<br>-ធ្វើចលនាដើរ លើកដៃ ក្រាបចុះ ងើបឡើង។ |
| ចរិយាសម្បទា | -អំណត់ព្យាយាម សហការគ្នា យកចិត្តទុកដាក់ធ្វើកិច្ចការ ទទួលស្គាល់ស្នាដៃរបស់ខ្លួនឯង និងអ្នកដទៃ។ |
| គ្រូបង្រៀន | បោះពុម្ពសន្លឹកកិច្ចការ (B3-PW-8_ល្បែងផាត់ពណ៌វដ្តឥន្ទធនូ) |
| កុមារ | សន្លឹកកិច្ចការ និងខ្មៅដៃពណ៌ |
| រៀបចំ | កន្លែងសម្រាប់លេង។ |

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
|---|---|---|

| | | |
|---|---|---|
| 1. ប្រាប់ក្មេងៗថានឹងឱ្យពួកគេសម្ដែងធ្វើជាវដ្ដជីវិតនៃទឹក។ ពួកគេនឹងសម្ដែងធ្វើជាទឹកដែរ។<br>2. បែងចែកក្មេងៗទៅជាក្រុមតូចៗ និងឱ្យពួកគេឈរជាក្រុមៗនៅតាមកន្លែងផ្សេង! ពីគ្នានៅក្នុងថ្នាក់។ ក្មេងៗត្រូវតែឈរនៅដាច់ដោយឡែកពីគ្នា។<br>3. ចូរឱ្យក្មេងៗទាំងអស់ក្រាបចុះ។<br>4. និយាយពាក្យថា រំហួត ការបង្រួម និងដំណក់ទឹក។<br>5. ប្រាប់ពួកគេគួរតែកន្លែកជើងម្ដងទៀតនៅក្នុងក្រុមរបស់ពួកគេ។<br>6. និយាយពាក្យហ្នឹងម្ដងទៀត និងឱ្យក្មេងៗទាំងអស់និយាយតាមអ្នក និងធ្វើកាយវិការដែរ។<br>7. ឱ្យក្មេងៗធ្វើដោយខ្លួនឯងផ្ទាល់ដោយគ្មានការនិយាយនិយាយអ្វីពីអ្នក។ ក្មេងៗត្រូវនិយាយពាក្យទាំងពម្នាក់ម្ដងៗ ឬម្នាក់និយាយមួយពាក្យក៏ | 1. **រំហួត៖** លើកដៃឡើងលើយឺត រហូតដល់កំពូល។<br>2. **ការបង្រួម៖** ផ្លាស់ប្ដូរទីទៅជិតៗអ្នកផ្សេងទៀតធ្វើដូចជាពពក។<br>3. **ដំណក់ទឹក៖** ក្រាបចុះ (ធ្វើដូចជាទឹកភ្លៀងធ្លាក់ចុះក្រោម)។ | 1. ចូលទៅក្នុងក្រុមដែលគ្រូរបស់អ្នកបានរៀបចំ<br>2. ឈរនៅកន្លែងដែលឆ្ងាយគ្នាបន្តិចពីក្មេងផ្សេងទៀត។<br>3. ឈរដោយមានភាពស្ងៀមស្ងាត់ និងចាំស្ដាប់ការណែនាំពីគ្រូរបស់អ្នក។<br>4. នៅពេលដែលគ្រូនិយាយពាក្យថា រំហួត អ្នកទាំងអស់គ្នាត្រូវងើបឡើងយឺតៗ និងធ្វើខ្លួនឱ្យត្រង់ទៅលើមេឃ។<br>5. ពាក្យធ្វើកាយវិការបង្រួមផ្លាស់ប្ដូរទីទៅជិតៗអ្នកផ្សេងទៀត ធ្វើដូចជាពពក។ តែកុំឈរនៅជិតគ្នាពេក។<br>6. ពាក្យដំណក់ទឹកធ្វើកាយវិការក្រាបចុះទៅនឹងតដ្ឋម្ដងទៀត។<br>7. ផ្លាស់ប្ដូរកន្លែងពីក្មេងៗទាំងអស់។<br>8. ថាតាមពាក្យដែលគ្រូរបស់អ្នកប្រាប់ និងព្យាយាមចងចាំពាក្យទាំងនោះ<br>9. និយាយពាក្យទាំងនោះម្ដងទៀត និងធ្វើកាយវិការដោយមិនមានការជួយពីអ្នកណាទាំងអស់។ |

| | | |
|---|---|---|
| បានអាស្រ័យលើការគិតរបស់អ្នក។<br>8. ចូរឱ្យក្មេងៗទាំងអស់អង្គុយចុះ។<br>9. ចូរចែកសន្លឹកកិច្ចការនិងខ្មៅដៃពណ៌។<br>10. ចូរឱ្យក្មេងៗទាំងអស់ផាត់ពណ៌លើសន្លឹកកិច្ចការរបស់ពួកគេ។ | | 10. អង្គុយចុះនៅពេលដែលគ្រូរបស់អ្នកប្រាប់អ្នកពីរឿងនោះ។<br>11. ផាត់ពណ៌ក្រដាសសន្លឹកកិច្ចការ។ |